00651553

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E53/2/1

# អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** មេធាវីការពារ អៀង សារី　　　**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១

**ពី:** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង និង
លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** អនុស្សរណៈឆ្លើយតបទៅនឹងសំណើដែលបានដាក់ដោយមេធាវីការពារ អៀង សារី (E53/2)

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់នូវ "សំណើសុំឱ្យមានការបញ្ជាក់ថាតើអង្គជំនុំជម្រះសាលាដំបូងមានបំណងធ្វើដូចម្តេច ក្រោយពេលទទួលនូវសំណើរបស់ភាគីដែលបានប្តឹងដិតចិត្តចៅក្រមទាំងអស់របស់អង្គជំនុំជម្រះ" ដែលបានដាក់ដោយមេធាវីការពារ អៀង សារី (ឯកសារ E53/2) ។ ដោយសំណើនេះធ្វើឡើងដោយមិនមាននូវមូលដ្ឋានផ្លូវច្បាប់ ហេតុដូច្នេះ អង្គជំនុំជម្រះសូមណែនាំថា៖

ក. អង្គភាពបកប្រែភាសាមិនចាំបាច់ធ្វើការបកប្រែឯកសារខាងលើជាភាសាខ្មែរ និងភាសាបារាំងនោះទេ ។

ខ. ភាគីទាំងអស់មិនតម្រូវឱ្យធ្វើការឆ្លើយតបទៅនឹងសំណើសុំនេះទេ ។

គ. បញ្ជូនបញ្ហានេះទៅអង្គភាពគាំពារការពារក្តីដើម្បីធ្វើការត្រួតពិនិត្យ ហើយដោយផ្អែកតាមសិទ្ធិអំណាចរបស់ខ្លួន អង្គភាពនេះអាចបដិសេធនូវការបង់ប្រាក់សម្រាប់ការងារដែលបានបំពេញ ក្នុងករណីដែលការងារនោះ "មិនមានភាពចាំបាច់ និងមិនសមស្រប" (មាត្រា F-10 នៃការណែនាំអំពីជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក) ហើយដោយផ្អែកតាមវិធាន១១-២(ជ) អង្គភាពនេះមាននូវសមត្ថកិច្ចក្នុងការ "ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ (រវាងអង្គភាពនេះជាមួយនឹងមេធាវីការពារជនជាប់ចោទ) និងអនុញ្ញាតឱ្យផ្តល់ប្រាក់កម្រៃស្របតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី"។

ឃ. អត្ថបទចម្លងនៃអនុស្សរណៈនេះត្រូវប្រគល់ទៅឱ្យលោកប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលដើម្បីជ្រាបជាព័ត៌មាន ។

អង្គជំនុំជម្រះសាលាដំបូង
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C · E C C C

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 03 / 2011
ម៉ោង (Time/Heure): 8:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun